# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬអង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Jan-2023, 08:33
CMS/CFO: Sann Rada

---

# សេចក្ដីសង្ខេបរបស់សហព្រះរាជអាជ្ញាស្ដីពីលក្ខខណ្ឌនៃការអនុវត្តទោស

---

**ដាក់ដោយ÷**

**សហព្រះរាជអាជ្ញា**

ជា លាង

Fergal GAYNOR

(បម្រុង)

**ដាក់ជូន÷**

**ចៅក្រមអង្គជំនុំជម្រះ**
**តុលាការកំពូល**

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម C. N. JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Phillip RAPOZA

ចៅក្រម យ៉ា ណារិន

**ជនជាប់ចោទ÷**

ខៀវ សំផន

**ក្រុមមេធាវីការពារក្ដី**

គង់ សំអុន

Anta GUISSÉ

## I. សេចក្តីផ្តើម

1. នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចយល់ព្រមតាមសំណើរបស់ ខៀវ សំផន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ សុំបង្គាប់ឱ្យសហព្រះរាជអាជ្ញា ផ្តល់ព័ត៌មានទាក់ទងនឹងផែនការលក្ខខណ្ឌនៃការឃុំខ្លួនគាត់នៅក្នុងពន្ធនាគារជាតិ បន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូលបានចេញសាលដីការួមជាមួយសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរ ក្នុងសំណុំរឿង ០០២/០២[1]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានស្នើសុំ "ការិយាល័យរដ្ឋបាលផ្តល់ជូនអង្គជំនុំជម្រះ និងភាគី នូវព័ត៌មានពាក់ព័ន្ធនឹងក្របខណ្ឌការងារដែលបានដាក់ចេញ ដោយក្នុងនោះរៀបរាប់លម្អិតអំពីនីតិវិធី ដែលយន្តការកេរដំណែលនឹងអនុវត្តជាក់ស្តែងនូវមុខងារសេសសល់ ក្នុងការត្រួតពិនិត្យការអនុវត្តទោសស្របគ្នាដែលបានកំណត់ជាកំហិតលើ ខៀវ សំផន ព្រមទាំងការតាមដានការប្រព្រឹត្តលើគាត់ក្នុងពេលកំពុងអនុវត្តទោសទាំងនោះ"2។

2. នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ អង្គជំនុំជម្រះតុលាការកំពូលបានចេញសាលដីការួមជាមួយសំអាងហេតុពេញលេញជាលាយលក្ខណ៍អក្សរក្នុងសំណុំរឿង ០០២/០២[3]។

3. នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ មេធាវីការពារក្តី ខៀវ សំផន បានដាក់ឯកសារ "សេចក្តីសង្កេតមុនការផ្ទេរទីឃុំឃាំងលោក ខៀវ សំផន ក្រោយពីការថ្លែងសម្អាងហេតុពេញលេញ នៅក្នុងសាលដីកានៃសំណុំរឿង ០០២/០២"[4]។ មេធាវីការពារក្តីបានបង្ហាញការព្រួយបារម្ភអំពីការថែទាំដែលនឹងផ្តល់ជូន ខៀវ សំផន ក្នុងពន្ធនាគារ ហើយបានស្នើសុំឱ្យមានការធានាលើការថែទាំសុខភាពគាត់មុនពេលផ្ទេររួមជាមួយនឹងការធានាអនុញ្ញាតឱ្យបុគ្គល ដែលក្រុមគ្រួសារគាត់បានកំណត់អត្តសញ្ញាណរួចរាល់អាចផ្តល់ជំនួយប្រចាំថ្ងៃ ទៅតាមតម្រូវការអាយុ និងស្ថានភាពរបស់គាត់។ មេធាវីការពារក្តីក៏បានគាំទ្រតាមសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះតុលាការកំពូលបង្កើតយន្តការត្រួតពិនិត្យផ្លូវការ ឬដំណើរការផ្ទេរការទទួលខុសត្រូវពី អ.វ.ត.ក ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង

---

[1] F77/1/1 សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំព័ត៌មានពីសហព្រះរាជអាជ្ញាស្តីពីផែនការនៃលក្ខខណ្ឌឃុំខ្លួន ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ ("សេចក្តីសម្រេចស្តីពីលក្ខខណ្ឌឃុំខ្លួន")។

[2] F77/1/1 សេចក្តីសម្រេចស្តីពីលក្ខខណ្ឌឃុំខ្លួន កថាខណ្ឌ ៣០។

[3] F76 សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។

[4] F79 សេចក្តីសង្កេតមុនការផ្ទេរទីឃុំឃាំងលោក ខៀវ សំផន ក្រោយពីការថ្លែងសម្អាងហេតុពេញលេញ នៅក្នុងសាលដីកានៃសំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ ("សេចក្តីសង្កេតរបស់ ខៀវ សំផន")។

បន្ថែមរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា[5]។

4. នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣ សហព្រះរាជអាជ្ញា ដោយគោរពតាមវិធាន ១១៣ នៃវិធានផ្ទៃក្នុង បានស្នើសុំអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ កំណត់ទីតាំងសមស្របមួយ សម្រាប់ ខៀវ សំផន អនុវត្តទោសដែលនៅសេសសល់ និងធានាលក្ខខណ្ឌឃុំឃាំងឲ្យបានសមស្រប សម្រាប់ ខៀវ សំផន រួមទាំងការជួសជុលកែបន្ទប់ឃុំឃាំងទៅតាមការចាំបាច់ ដើម្បីបំពេញតាមតម្រូវការចល័តទីរបស់គាត់ និងការបន្តការថែទាំសុខភាព និងការថែទាំប្រចាំថ្ងៃជូន ខៀវ សំផន ក្នុងពេលជាប់ពន្ធនាគារ។ សហព្រះរាជអាជ្ញាក៏បានស្នើសុំបន្ថែមឲ្យបន្តឃុំ ខៀវ សំផន នៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក រហូតដល់ពេលសហព្រះរាជអាជ្ញា និងអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ ឯកភាពលើទីតាំងពន្ធនាគារសមស្របមួយ សម្រាប់ឃុំខ្លួន ខៀវ សំផន ដើម្បី អនុវត្តទោសដែលនៅសេសសល់។

5. ឯកសារនេះបានធ្វើឡើងដើម្បីជូនដំណឹងដល់អង្គជំនុំជម្រះតុលាការកំពូល ការិយាល័យរដ្ឋបាល និងមេធាវីការពារក្តី ខៀវ សំផន អំពីវិធានការ ដែល ក.ស.ព បានធ្វើឡើង ដើម្បីផ្តួចផ្តើមលើការអនុវត្តទោសដែលនៅសេសសល់របស់ ខៀវ សំផន ក្នុងលក្ខខណ្ឌឃុំខ្លួនឲ្យបានសមស្រប។

6. ការចាប់ផ្តើមនៃការអនុវត្តទោស លក្ខខណ្ឌនៃការឃុំខ្លួន និងការត្រួតពិនិត្យលក្ខខណ្ឌទាំងនោះមានភាពប្រទាក់ក្រឡាគ្នាមិនអាចកាត់ផ្តាច់បាន។ ក.ស.ព បានស្នើសុំឲ្យធ្វើការផ្ទេរទៅពន្ធនាគារជាតិ ឲ្យបានទាន់ពេលវេលា ស្របតាមលក្ខខណ្ឌនៃការឃុំខ្លួនស្តីពីបទដ្ឋានអន្តរជាតិស្តីពីការប្រព្រឹត្តចំពោះអ្នកទោស រួមទាំងការផ្តល់ការរៀបចំផ្នែកដឹកជញ្ជូន និងផ្នែកវេជ្ជសាស្ត្រពិសេសដែល ខៀវ សំផន ត្រូវការចំបាច់ផងដែរ។

## II. ស្ថានភាពខណៈពេលបច្ចុប្បន្ន

7. ស្ថានភាពបច្ចុប្បន្នខុសប្លែកពីករណីធម្មតា។ ខៀវ សំផន មានអាយុ ៩១ឆ្នាំ ប្រើរទេះរុញ និងអាចចល័តទីបានខ្លះតែប៉ុណ្ណោះ។ [redacted] កាលៈទេសៈទាំងនេះបង្កជាបញ្ហាប្រឈមដល់ ក.ស.ព ចំពោះការឯកភាពលើការចាប់ផ្តើមអនុវត្តទោសអនុលោមតាមវិធាន ១១៣ នៃវិធានផ្ទៃ ក្នុងលក្ខខណ្ឌឃុំខ្លួនឲ្យបានសមស្រប និងសម្រាប់អគ្គនាយកពន្ធនាគារ ក្រសួងមហាផ្ទៃ ក្នុងការអនុវត្តលក្ខខណ្ឌទាំងនោះ។ កាលៈទេសៈ

---

[5] F79 សេចក្តីសង្កេតរបស់ ខៀវ សំផន កថាខណ្ឌ ៣-៥។

ទាំងនេះក៏តម្រូវឲ្យ អ.វ.ត.ក បំពេញភារកិច្ចរបស់ខ្លួន ភ្លាមៗ និងដោយមានការប្រុងប្រយ័ត្ន អនុលោមតាមកិច្ចព្រមព្រៀងបន្ថែមរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា[6] ស្តីពីការតាមដានការប្រព្រឹត្តចំពោះទណ្ឌិត។

8. ដូចអង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ ក.ស.ព បានខិតខំជាច្រើនលើកច្រើនសាកាលពីខែមេសា និងខែឧសភា ឆ្នាំ២០២២ ស្វែងរកព័ត៌មានពាក់ព័ន្ធនឹងការថែទាំ ខៀវ សំផន ហើយក៏បានលើក "សំណួរជាច្រើនផ្សេងៗគ្នាដូចជា *ក្នុងចំណោមទោះ*ពាក់ព័ន្ធទៅនឹងតម្រូវការពិសេសរបស់ ខៀវ សំផន វិធានការការពារជំងឺឆ្លងកូវីដ-១៩ ក្នុងការសម្រួលដល់ការចូលសួរសុខទុក្ខ សិទ្ធិទទួលបានការចូលសួរសុខទុក្ខ និងការរឹតត្បិតផ្នែកសុខភាពស្តីពីការចូលសួរសុខទុក្ខ អត្ថិភាពនៃបុគ្គលិកពេទ្យប្រចាំការពេញម៉ោង និងតួនាទី បទប្បញ្ញត្តិសម្រាប់ការសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ និងបទដ្ឋានប្រតិបត្តិការនីតិវិធី ឬបទបញ្ជា"[7]។

9. ក្រៅពីការសាកសួរព័ត៌មានទាំងនោះ ក.ស.ព ក៏បានទទួលចម្លើយតបពី ឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ ១ ឆែម សាវុធ អគ្គនាយកពន្ធនាគារ ក្រសួងមហាផ្ទៃ និង ឯកឧត្តម ថោង សុជាតិ ដាច់ដោយឡែកពីគ្នា កាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២២ និងថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២។ ចម្លើយតបទៅនឹងសំណួរជាបន្តបន្ទាប់ ក៏បានទទួលពី ឯកឧត្តម ថោង សុជាតិ កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ ផងដែរ។

10. យោងតាមចម្លើយតបពី ឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ ១ ឆែម សាវុធ និង ឯកឧត្តម ថោង សុជាតិ បានផ្តល់ព័ត៌មានដូចខាងក្រោម៖

ក. ខៀវ សំផន មានបញ្ហាពិបាកចល័តទីខ្លាំង។ [redacted]។

---

[6] កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យស្តីពីការរៀបចំក្នុងពេលអន្តរកាលនិងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ និងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ មាត្រា ២(១)។

[7] F77/1/1 សេចក្តីសម្រេចស្តីពីលក្ខខណ្ឌឃុំខ្លួន កថាខណ្ឌ ១៩។

ខ. ខៀវ សំផន ត្រូវការ របបថ្នាំប្រចាំថ្ងៃមួយចំនួន ដូចបានផ្ដល់ជូនក្នុងពេលបច្ចុប្បន្ន សម្រាប់ [redacted] របបថ្នាំបន្ថែម បានចេញទៅតាមតម្រូវការចាំបាច់ដើម្បីព្យាបាល [redacted]

គ. [redacted]

ឃ. ខៀវ សំផន បានទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ចំនួន ០៤ដង និង

ង. [redacted] និង វេជ្ជបណ្ឌិតម្នាក់ នៅប្រចាំការ ២៤ម៉ោងក្នុងមួយថ្ងៃ។ [redacted] ល្ពិកណាមានគ្រូពេទ្យសម្រាប់ទាក់ទងបានគឺគ្រប់គ្រាន់។ ក្នុងករណីត្រូវការជំនួយសង្គ្រោះបន្ទាន់ផ្នែកវេជ្ជសាស្ត្រ រួមទាំងការថែទាំបន្ទាន់ គាត់គួរបញ្ជូនទៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតតែម្ដង។

## III. ការចុះពិនិត្យពន្ធនាគារខេត្តកណ្ដាល កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២

11. ក.ស.ព បានចុះពិនិត្យពន្ធនាគារខេត្តកណ្ដាល កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ និងបានជួបពិភាក្សាជាមួយលោក ឈាវ ស្រេង ព្រះរាជអាជ្ញាខេត្តកណ្ដាល លោក ឯក ស៊ុនរស្មី និងវេជ្ជបណ្ឌិត ហែម កុសល គ្រូពេទ្យប្រចាំពន្ធនាគារខេត្តកណ្ដាល។ បន្ទាប់មក ក.ស.ព. ក៏បានផ្ញើអនុស្សរណៈលម្អិតមួយច្បាប់អំពីដំណើរចុះពិនិត្យទីតាំងនោះជូនការិយាល័យរដ្ឋបាល។

12. ក្នុងអំឡុងពេលចុះពិនិត្យទីតាំង ក.ស.ព. បានពិនិត្យបន្ទប់ពីរកន្លែង ដែលអាចជ្រើសយក ជាទីតាំងឃុំខ្លួន ខៀវ សំផន ហើយបន្ទាប់មកបានជួបពិភាក្សាជាមួយព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង និងវេជ្ជបណ្ឌិត។

13. បន្ទប់ទី១ ធ្លាប់ប្រើប្រាស់ឃុំ កាំង ហ្កេកអ៊ាវ ហៅ ឌុច។ ក.ស.ព យល់ឃើញថា បន្ទប់នេះមិនសក្តិសមសម្រាប់ឃុំ ខៀវ សំផន តាមស្ថានភាពអាយុបច្ចុប្បន្នរបស់គាត់ ក្នុងវ័យ ៩១ឆ្នាំ ដោយសារបញ្ហាចំបងគឺបណ្ដាលមកពីបញ្ហាពិបាកបររទេះរុញចេញ-ចូល [redacted] ហើយបន្ទប់នេះ ពុំមានកន្លែងសម្រាប់អ្នកមើលថែទាំ។

14. ក.ស.ព. ក៏បានចូលពិនិត្យបន្ទប់ទីពីរដែលអាចប្រើសម្រាប់ឃុំខ្លួន ដែលបន្ទប់នេះពីមុនជាបន្ទប់ប្រជុំបុគ្គលិក និងឃ្លាំងផ្ទុកសម្ភារៈ។ បន្ទប់នេះ ពុំទាន់បានជួសជុលកែទៅជាបន្ទប់ឃុំនៅឡើយទេ។ [redacted]

15. ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង និងវេជ្ជបណ្ឌិតប្រចាំពន្ធនាគារខេត្តកណ្ដាល បានផ្ដល់ជូននូវព័ត៌មានបន្ថែមដូចខាងក្រោម៖

ក. ពន្ធនាគារនឹងមិនផ្ដល់ជូនអ្នកមើលថែទាំ ឬ បុគ្គលណាមួយក្នុងតួនាទីស្រដៀងនេះចាំជួយ ខៀវ សំផន [redacted] ព្រះរាជអាជ្ញា ឈាវ ស្រេង បានស្នើសុំឲ្យសមាជិកគ្រួសារ ខៀវ សំផន ណាម្នាក់ ឬច្រើននាក់ មកបំពេញតួនាទីនេះ ហើយអនុញ្ញាតឲ្យពួកគេមានសិទ្ធិចេញ-ចូល ពន្ធនាគារក្នុងគោលបំណងនេះ។

ខ. តាមទម្លាប់កន្លងមក ពុំដែលមានថ្នាំពេទ្យរក្សាទុកជាប់ជាប្រចាំនៅក្នុងបរិវេណពន្ធនាគារនោះទេ។ ក៏ប៉ុន្តែ មានការឯកភាពថា របបថ្នាំគ្រូពេទ្យចេញជូន ខៀវ សំផន និងបានបញ្ជូនទៅពន្ធនាគារ នឹងត្រូវរក្សាទុកនៅទីនោះក្រោមការត្រួតពិនិត្យរបស់វេជ្ជបណ្ឌិត ឯម កុសល និងផ្ដល់ជូនដោយគិលានុបដ្ឋាកទៅតាមរបបកំណត់។

គ. ប្រសិនបើ ខៀវ សំផន ឈឺ គាត់នឹងត្រូវបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យខេត្តកណ្ដាល។ ប្រសិនបើមិនអាចផ្ដល់ការព្យាបាលសមស្របនៅទីនោះបាន គាត់នឹងត្រូវបញ្ជូនបន្តទៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតក្នុងរាជធានីភ្នំពេញ។

ឃ. ការចូលសួរសុខទុក្ខជាលក្ខណៈគ្រួសារ/ភ្ញៀវ មានភាពបត់បែន ហើយអាចមានការរៀបចំឲ្យសាច់ញាតិ ខៀវ សំផន ស្នាក់នៅក្នុងបន្ទប់ឃុំតែម្ដង។

ង. ថវិកាសម្រាប់ម្ហូបអាហារទណ្ឌិត មានចំនួន ៣.៥០០រៀលក្នុងមួយថ្ងៃ។ ដោយសារត្រូវការសន្សំសំចៃ និងមានរបបអាហារបន្ថែមដាំដុះនៅក្នុងបរិវេណពន្ធនាគារ អាចគ្រប់គ្រាន់សម្រាប់អាហារចំនួនពីរពេលក្នុងមួយថ្ងៃសម្រាប់ទណ្ឌិតម្នាក់។ សាច់ញាតិក៏ត្រូវបានលើកទឹកចិត្តឲ្យយកអាហារជូនអ្នកជាប់ឃុំផងដែរ។

ច. គ្រួសារអាចយកសៀវភៅ និងកាសែតមកជូនអ្នកទោសបាន ប៉ុន្តែត្រូវឆ្លងកាត់ការពិនិត្យសិន។

ឆ. នីតិវិធីសម្រាប់ការទប់ស្កាត់ការរីករាលដាលការឆ្លងជំងឺកូវីដ-១៩ បានទទួលជោគជ័យមកទល់សព្វថ្ងៃ ប៉ុន្តែមិនមានការបញ្ជាក់ជាក់លាក់ណាមួយអំពីនីតិវិធីទាំងនោះឡើយ។

16. ក.ស.ព ដាក់របាយការណ៍វាយតម្លៃជូនការិយាល័យរដ្ឋបាលអំពីដោយបានគូសបញ្ជាក់ថា គិតត្រឹមថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ មិនមានកន្លែងឃុំសមស្របក្នុងពន្ធនាគារខេត្តកណ្ដាល សម្រាប់ ខៀវ សំផន ក្នុងស្ថានភាពសុខភាព និងចល័តទីបច្ចុប្បន្នរបស់គាត់។ ក.ស.ព ក៏បានកត់សម្គាល់ផងដែរថា បញ្ហាចំបងមួយទៀតគឺការកន្លែងសម្រាប់អ្នកមើលថែទាំ។ [redacted] យោងតាមអាយុ ស្ថានភាព ខៀវ សំផន មិនអាចសន្មតថានឹងប្រសើរឡើងវិញបានឡើយនោះទេ។ ផ្ទុយទៅវិញ តាមការសន្មត ស្ថានភាពគាត់នឹងកាន់តែដុនដាបជាងមុន។ ការពឹងអាស្រ័យលើសមាជិកគ្រួសារដើម្បីបំពេញតួនាទីនេះ មិនមែនជាដំណោះស្រាយដែលយើងចង់បាននោះទេ។

17. ក.ស.ព បានសន្និដ្ឋានថា ក.ស.ព. ជូនអនុសាសន៍សូមកុំទាន់ធ្វើការផ្ទេរ រហូតទាល់តែមានការរៀបចំរួចរាល់ ដើម្បីធានាថា របបថ្នាំតម្រូវគ្រប់បែបយ៉ាង [redacted] ហើយនឹងមានការផ្ដល់ជូនអ្នកមើលថែទាំ។ ក.ស.ព បានលើកអនុសាសន៍ចំនួន ០៣ ជូនការិយាល័យរដ្ឋបាល៖

ក. ទីតាំងទីពីរអាចជាបន្ទប់ឃុំ ត្រូវបានជួសជុលកែលម្អស្របតាមបទដ្ឋានចាំបាច់ ដោយបានគិតគូរអំពីតម្រូវការភស្តុភាររបស់ ខៀវ សំផន។

ខ. ចាំបាច់ត្រូវរៀបចំឲ្យមានអ្នកមើលថែទាំជាប់ ២៤ម៉ោងក្នុងមួយថ្ងៃ [redacted] ដូច្នេះចាំបាច់ត្រូវការមានថវិកាសម្រាប់គោលបំណងនេះ។

គ. ការរៀបចំឲ្យមានរបបថ្នាំតាមវេជ្ជបញ្ជាជូន ខៀវ សំផន និងបញ្ជូនទៅពន្ធនាគារតាមការតម្រូវ។ មុនពេលមានការផ្ទេរ ខៀវ សំផន គួរទទួលការពិនិត្យសុខភាព ហើយវេជ្ជបញ្ជាចេញចុងក្រោយបំផុតត្រូវផ្ដល់ជូនមន្ទីរពេទ្យផ្ដល់ថ្នាំ/ឱសថស្ថាន។

## IV. ក.ស.ព ចុះពិនិត្យទីតាំងពន្ធនាគារខេត្តកណ្តាលនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២

18. នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិបម្រុងបាន ចុះពិនិត្យពន្ធនាគារខេត្តកណ្តាលនិងបានជួបពិភាក្សាជាមួយតំណាងអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ រួមមាន ឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ ១ ម៉ៅ សុភារម្យ អគ្គនាយករង នៃ អគ្គនាយកដ្ឋានពន្ធនាគារ និងលោក លោក ឯម និមល ប្រធានពន្ធនាគារខេត្តកណ្តាល។ វត្តមានក្នុង ឱកាសនោះផងដែរ រួមមាន លោក ឯក ស៊ុនរស្មី ព្រះរាជអាជ្ញារង។

19. មន្ត្រីពន្ធនាគារខេត្តកណ្តាល បានបង្ហាញបន្ទប់មួយ ជូន ក.ស.ព ពិនិត្យ ដែលបន្ទប់នេះកំពុង ជួស ជុលកែលម្អ ក្នុងនោះក៏បានបញ្ជាក់ផងដែរថា បន្ទប់នេះជួសជុលហើយបានច្រើនចាប់តាំងពីពេល ក .ស.ព ចុះពិនិត្យមើល កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២។ តាមការយល់ឃើញរបស់សហព្រះ រាជអាជ្ញា បន្ទប់នេះអាចទទួលយកបានដោយសារ វាធំទូលាយ មានគ្រែពីរ និងមានកន្លែងគ្រប់គ្រាន់ សម្រាប់ ខៀវ សំផន និងអ្នកមើលថែទាំ។ បន្ទប់នេះ មានកន្លែងហាត់ប្រាណឯកជនតូចល្មម មាន ខ្យល់អាកាសចេញ-ចូលគ្រប់គ្រាន់ មានកង្ហារជាប់ពិដាន [redacted] ខៀវ សំផន នឹងនៅឃុំដាច់ ដោយឡែកឆ្ងាយល្មមពីអ្នកទោសផ្សេងទៀត ហើយក្នុងករណីជំងឺកូវីដ-១៩ ផ្ទុះឡើងនៅក្នុង ពន្ធនាគារ ទីតាំងបន្ទប់នេះអាចការពារគាត់មិនឲ្យឆ្លងបាន។

20. ក.ស.ព បានលើកឡើងជូនមន្ត្រីពន្ធនាគារ អំពីការងារកែជួសជុលបន្ទប់ ដែលការងារនេះកំពុងបន្ត ដំណើរការ ក្នុងនោះរួមទាំងការដំឡើងក្បាលផ្កាឈូកងូតទឹក របារសម្រាប់ទប់ពេលចល័តទីនៅក្នុង បន្ទប់ទឹក និងជម្រាលតូចមួយ ដើម្បីអាចឲ្យរទេះរុញបរចេញ-ចូលស្រួល។

21. កិច្ចប្រជុំរវាង ក.ស.ព និងអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ បានលើកឡើងអំពី៖ (ក) ការ ធ្វើលំហាត់ប្រាណរបស់ ខៀវ សំផន និងសិទ្ធិចូលសួរសុខទុក្ខសម្រាប់ភ្ញៀវ និងមេធាវីរបស់គាត់ (ខ) ការថែទាំសុខភាព (គ) អ្នកមើលថែទាំ។

22. ក.ស.ព បានពន្យល់ថា យោងតាមលក្ខខណ្ឌនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ ប្រសិនបើការរៀបចំដែល "ធានាលក្ខខណ្ឌនៃការឃុំខ្លួនគ្រប់គ្រាន់ សម្រាប់ ខៀវ សំផន នៅតែមិនទាន់រួចរាល់មកទល់ពេលចេញសាលដីកាមានសំអាងហេតុពេញ លេញក្នុងសំណុំរឿង ០០២/០២ នោះ ខៀវ សំផន ត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក រហូត

ដល់មានការរៀបចំសមស្របត្រូវបានធ្វើឡើងដោយសហព្រះរាជអាជ្ញា"[8]។ សហព្រះរាជអាជ្ញាក៏បានពន្យល់ផងដែរថា អង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញការយល់ឃើញថា "ព័ត៌មានដែលបានស្នើសុំដោយ ខៀវ សំផន រួមទាំងទីតាំងនៃការឃុំឃាំង ការជួយសម្រួលផ្នែកវេជ្ជសាស្ត្រ និងការកែប្រែបន្ទប់ឃុំខ្លួនរបស់គាត់ដើម្បីជួយសម្រួលដល់ការផ្លាស់ទីរបស់គាត់ចាំបាច់នោះ ជាការសមហេតុផល និងបានប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិរបស់គាត់ក្នុងការទទួលបានលក្ខខណ្ឌនៃការឃុំឃាំងដោយមនុស្សធម៌ និងគ្រប់គ្រាន់"[9]។

23. ចំពោះប្រធានបទនៃការធ្វើលំហាត់ប្រាណ និងសិទ្ធិចូលសួរសុខទុក្ខ មន្ត្រីពន្ធនាគារបានជម្រាបជូន ក.ស.ព ថា៖

ក. ខៀវ សំផន នឹងអាចផ្លាស់ទីពីកន្លែងហាត់ប្រាណទៅបន្ទប់ឃុំរបស់គាត់តាមចិត្តចាប់ពីម៉ោង ០៧០០ ដល់ម៉ោង ១១០០ និងចាប់ពីម៉ោង ១៤០០ ដល់ម៉ោង ១៧០០ ជារៀងរាល់ថ្ងៃ។

ខ. ដោយសារបន្ទប់ឃុំ ខៀវ សំផន ជាបន្ទប់ឯកជន គាត់មិនអាចនៅលាយឡំជាមួយអ្នកទោសផ្សេងទៀតទេ។ គាត់អាចទទួលភ្ញៀវនៅម៉ោង ០៨០០-១១០០ និង ១៤០០-១៧០០ ចាប់ពីថ្ងៃច័ន្ទរហូតដល់ថ្ងៃសៅរ៍។ គ្រួសារគាត់អាចយកម្ហូបអាហារជូនគាត់ក្នុងអំឡុងពេលម៉ោងចូលសួរសុខទុក្ខបាន។

គ. មេធាវីរបស់គាត់អាចចូលសួរសុខទុក្ខ និងពិភាក្សាជាមួយគាត់ក្នុងអំឡុងម៉ោងសួរសុខទុក្ខ ហើយអាចបង្ហាញឯកសារជូនគាត់។

ឃ. ការចូលសួរសុខទុក្ខអ្នកទោស រួមទាំង ខៀវ សំផន ធ្វើឡើងដោយមានវត្តមានអនុរក្សពន្ធនាគារមួយរូប។

24. ពាក់ព័ន្ធនឹងការថែទាំសុខភាព ឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ ១ ម៉ៅ សុភារម្យ អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធនាគារ បានមានប្រសាសន៍ថា៖

ក. ឯកឧត្តម ធ្លាប់ទទួលការងារឃុំខ្លួន ខៀវ សំផន នៅ អ.វ.ត.ក និងបានដឹកនាំការ

---

[8] F77/1/1 សេចក្តីសម្រេចស្តីពីលក្ខខណ្ឌឃុំខ្លួន កថាខណ្ឌ ២៣។

[9] F77/1/1 សេចក្តីសម្រេចស្តីពីលក្ខខណ្ឌឃុំខ្លួន កថាខណ្ឌ ២៥។

រៀបចំបន្ទប់ឃុំដែលរៀបចំថ្មីជូន ខៀវ សំផន នៅខេត្តកណ្ដាល។

ខ. នៅកម្ពុជា មិនមានទីតាំងឃុំឃាំងពិសេសសម្រាប់ជនជាប់ឃុំ ដូច ខៀវ សំផន នោះទេ។ កាលៈទេសៈរបស់ ខៀវ សំផន គឺជាករណីពិសេស ដូច្នេះទើបជាយើងបានព្យាយាមសង់បន្ទប់ឃុំមួយទៅតាមកាលៈទេសៈនេះ។

គ. ពន្ធនាគារខេត្តកណ្ដាលមិនបានទទួលរបាយការណ៍ពេទ្យពី អ.វ.ត.ក នៅឡើយទេ។ បញ្ហាពេទ្យទាក់ទងនឹងទណ្ឌិត គឺជាបន្ទុករបស់ក្រសួងសុខាភិបាល។ មន្ត្រីពន្ធនាគារខេត្តកណ្ដាលនៅមិនទាន់ដឹងនៅឡើយទេថាតើរបបថ្នាំអ្វីខ្លះដែលបានចេញជូន ខៀវ សំផន នាពេលបច្ចុប្បន្ន ហើយបុគ្គលណាទទួលខុសត្រូវចែកថ្នាំទាំងនោះជូនទៅពន្ធនាគារខេត្តកណ្ដាលបន្ទាប់ពីមានការផ្ទេរមក។

ឃ. ពន្ធនាគារខេត្តកណ្ដាលអាចធានាបានឲ្យមានគិលានុបដ្ឋាក ជាអ្នកចែកថ្នាំចាំបាច់ជូន ខៀវ សំផន [redacted]

ង. យោងតាមច្បាប់ជាធរមានស្ដីពីពន្ធនាគារ សុខភាពអ្នកទោសទាំងអស់ស្ថិតនៅក្រោមក្រសួងសុខាភិបាល។ ជំងឺស្រាលត្រូវបានព្យាបាលនៅពន្ធនាគារខេត្តកណ្ដាល។ ចំពោះជំងឺធ្ងន់ធ្ងរ អ្នកទោសត្រូវបញ្ជូនទៅមន្ទីរពេទ្យដែលមានទីតាំងមិនលើសមួយគីឡូម៉ែត្រពីពន្ធនាគារខេត្តកណ្ដាល (មន្ទីរពេទ្យជ័យជំនះ)។

ច. ទាក់ទងនឹងអនុសាសន៍របស់គ្រូពេទ្យ អ.វ.ត.ក ឱ្យ ខៀវ សំផនពិនិត្យសុខភាពរៀងរាល់ប្រាំមួយខែម្ដងនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មន្ត្រីពន្ធនាគារជាទូទៅអនុវត្តអនុសាសន៍ធ្វើឡើងដោយវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យខេត្តកណ្ដាល។

ឆ. មន្ត្រីពន្ធនាគារខេត្តកណ្ដាលចង់បានវេជ្ជបណ្ឌិត ដែលចាត់តាំងពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដើម្បីមើលថែទាំ ខៀវ សំផន។ មន្ត្រីពន្ធនាគារយល់ស្របថា រឿងសំខាន់គឺគ្រូពេទ្យព្យាបាលមានព័ត៌មានលម្អិតពេញលេញអំពីតម្រូវការវេជ្ជសាស្ត្ររបស់ ខៀវ សំផន ក៏ដូចជាការរៀបចំឲ្យបានច្បាស់លាស់អំពី ការបញ្ជូនគ្រប់របបថ្នាំចាំបាច់ជូនទៅមន្ទីរពេទ្យខេត្តកណ្ដាល។

ជ. អាស្រ័យហេតុនេះ មន្ត្រីពន្ធនាគារសូមជូនជាអនុសាសន៍ថា នៅថ្ងៃខាងមុខ គួរបន្ត

រៀបចំដូចពេលបច្ចុប្បន្ន ដែលមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ទទួលបន្ទុកដំបូងក្នុងការព្យាបាល ខៀវ សំផន និងការផ្ដល់គ្រប់របបថ្នាំចាំបាច់ជូនគាត់ ត្រូវបន្តធ្វើដូច្នេះសម្រាប់ថ្ងៃខាងមុខ។

ឈ. មន្ត្រីពន្ធនាគារខេត្តកណ្ដាល ក៏សូមស្នើមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ចាត់តាំងគ្រូពេទ្យរូបណា ដែលអាចមើលថែទាំ ខៀវ សំផន ពេញម៉ោង ព្រមទាំងរថយន្តសង្គ្រោះផងដែរ។

25. ចំពោះប្រធានបទអំពីការផ្ដល់អ្នកមើលថែទាំសម្រាប់ជួយ ខៀវ សំផន [redacted] មន្ត្រីពន្ធនាគារបានលើកឡើងចំណុចដូចខាងក្រោម៖

ក. យោងតាមច្បាប់ស្ដីពីពន្ធនាគារកម្ពុជា ពុំមានបទប្បញ្ញត្តិណាមួយចែងអំពីការផ្ដល់សេវាថែទាំពេញម៉ោង ដើម្បីជួយអ្នកទោសនោះទេ ហើយពន្ធនាគារខេត្តកណ្ដាល ក៏មិនចាត់តាំង ឬជួលអ្នកមើលថែពេញម៉ោងចាំជួយ ខៀវ សំផន នោះដែរ។

ខ. មន្ត្រីពន្ធនាគារបានដឹងថា អ្នកមើលថែប្រចាំ អ.វ.ត.ក ដែលបាន និងកំពុងមើលថែ ខៀវ សំផន ដឹងអំពីស្ថានភាពសុខភាព ខៀវ សំផន និងមានបទពិសោធន៍មើលថែទាំគាត់ប្រចាំថ្ងៃ។

គ. មន្ត្រីពន្ធនាគារអាចអនុវត្តសេវាដូចគ្នានៅពន្ធនាគារខេត្តកណ្ដាល ដោយប្រើប្រាស់អ្នកមើលថែដដែល។ ដូច្នេះ មន្ត្រីពន្ធនាគារនឹងជួយសម្រួលឲ្យអ្នកមើលថែទាំទាំងនោះអាចចេញ-ចូល មើលថែ ខៀវ សំផន ២៤ម៉ោងក្នុងមួយថ្ងៃ។ ប៉ុន្តែ មន្ត្រីពន្ធនាគារនឹងមិនជួលអ្នកមើលថែទាំដោយខ្លួនឯងផ្ទាល់សម្រាប់ផ្ដល់សេវានេះទេ។

26. អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ បានសង្កត់ធ្ងន់ថា ឯកឧត្តម យកចិត្តទុកដាក់លើការងារជួសជុលកែបន្ទប់តាមសំណើសុំរបស់ ក.ស.ព ដើម្បីគោរពតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល។ ឯកឧត្តម បានកត់សម្គាល់ថា ឯកឧត្តម មានបទពិសោធន៍កិច្ចសហប្រតិបត្តិការដ៏ជោគជ័យជាមួយ អ.វ.ត.ក ក្នុងពេលកន្លងមក ហើយ ឯកឧត្តម ចង់ឲ្យការងារនេះជោគជ័យបន្តទៀត។ ឯកឧត្តម បានស្នើឲ្យ ក.ស.ព សុំឲ្យអាជ្ញាធរពាក់ព័ន្ធផ្ដល់អ្នកមើលថែទាំ និងមានកិច្ចព្រមព្រៀងជាមួយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតបន្តទៀត។ ក.ស.ព បានទទួលយក

អនុសាសន៍នឹងបានធ្វើការទាក់ទងការិយាល័យរដ្ឋបាលលើបញ្ហាទាំងពីរនេះ។

## V. ក.ស.៣ ចុះពិនិត្យទីតាំងពន្ធនាគារខេត្តកណ្ដាលនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣

27. នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិបម្រុង បានចុះពិនិត្យការងារជួសជុលកែលម្អបន្ទប់ឃុំដែលមន្ត្រីពន្ធនាគារខេត្តកណ្ដាលបានជួសជុលកាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ [redacted] សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិបម្រុង មានការពេញចិត្តលើការអនុវត្តការងារទាំងនេះ ហើយពិនិត្យឃើញថា បន្ទប់ និងកន្លែងហាត់ប្រាណសមស្របសម្រាប់គោលដៅកំណត់។

## VI. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍របស់ ក.ស.៣

28. សហព្រះរាជអាជ្ញាគូសបញ្ជាក់ថា ការត្រួតពិនិត្យការអនុវត្តទោស ក៏ដូចជាការតាមដានការប្រព្រឹត្តចំពោះទណ្ឌិត សម្រាប់រយៈពេលបីឆ្នាំដំបូង គឺជាការទទួលខុសត្រូវរបស់ អ.វ.ត.ក អនុលោមតាមកិច្ចព្រមព្រៀងបន្ថែមរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា ហើយអង្គជំនុំជម្រះតុលាការកំពូលបានស្នើសុំឱ្យការិយាល័យរដ្ឋបាលផ្ដល់ព័ត៌មានទាក់ទងនឹងនីតិវិធី ដែល អ.វ.ត.ក នឹងអនុវត្តក្នុងការបំពេញភារកិច្ចត្រួតពិនិត្យការអនុវត្តទោស ខៀវ សំផន និងការតាមដានការប្រព្រឹត្តលើគាត់[10]។ សហព្រះរាជអាជ្ញាទទួលស្គាល់ថា ការរៀបចំផ្នែកវេជ្ជសាស្ត្រដែលនឹងធ្វើឡើងនាពេលខាងមុខ ចាំបាច់ត្រូវគិតគូរអំពីយោបល់របស់អគ្គនាយកដ្ឋានពន្ធនាគារ និងពន្ធនាគារខេត្តកណ្ដាល។ សហព្រះរាជអាជ្ញាក៏បានដឹងថា គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម ធ្វើការចុះពិនិត្យពន្ធនាគារទូទាំងប្រទេសកម្ពុជាជាទៀងទាត់ រួមទាំងពន្ធនាគារខេត្តកណ្ដាលផងដែរ។

29. យោងតាមព័ត៌មានផ្ដល់ជូនដោយអគ្គនាយកពន្ធនាគារ ក្រសួងមហាផ្ទៃ និងដោយគិតគូរអំពីអាយុបច្ចុប្បន្ន លទ្ធភាពចល័តទី និងតម្រូវការផ្នែកវេជ្ជសាស្ត្រ ស្តង់ដារឃុំឃាំងជាលក្ខណៈជាតិ និងអន្តរជាតិ (រួមទាំងច្បាប់ស្តីពីពន្ធនាគារកម្ពុជា ឆ្នាំ២០១១ និង វិធានបទដ្ឋានអប្បបរមានៃអង្គការសហប្រជាជាតិស្តីពីការប្រព្រឹត្តចំពោះអ្នកទោស) សហព្រះរាជអាជ្ញាយល់ឃើញថា បន្ទប់ឃុំ និងកន្លែងហាត់ប្រាណឯកជន នៅពន្ធនាគារខេត្តកណ្ដាលសម្រាប់ ខៀវ សំផន មានលក្ខណៈសមស្របអាចឱ្យគាត់បន្តអនុវត្តទោសនៅទីនោះបាន។

---

[10] F77/1/1 សេចក្ដីសម្រេចស្ដីពីលក្ខខណ្ឌឃុំខ្លួន កថាខណ្ឌ ២៩។

30. សហព្រះរាជអាជ្ញាបានដាក់ជូនអនុសាសន៍ចំនួនពីរបន្ថែម ជូនការិយាល័យរដ្ឋបាលរួចហើយ ទាក់ទងនឹងការរៀបចំការថែទាំ ដែលបច្ចុប្បន្នកំពុងស្ថិតក្រោមការទទួលខុសត្រូវរបស់ការិយាល័យរដ្ឋបាល។ អាស្រ័យដូចបានជម្រាបជូនខាងលើ អនុសាសន៍ទាំងពីរនេះ មានការការគាំទ្រយ៉ាងពេញទំហឹងពីអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធនាគារ។ សហព្រះរាជអាជ្ញាអាចអនុញ្ញាតឲ្យធ្វើការផ្ទេរអនុលោមតាមវិធាន ១១៣ នៃវិធានផ្ទៃក្នុង នាពេលខាងមុខឆាប់ៗ ក្រោយទទួលបានការធានាពីការិយាល័យរដ្ឋបាលអំពីការអនុវត្ត អនុសាសន៍ចំនួនពីរដូចខាងក្រោម៖

១. ការងាររៀបចំជាមួយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត អំពីការបន្តព្យាបាល ខៀវ សំផន ដើម្បីឱ្យគាត់ទទួលបានរបបថ្នាំ (ទាំងរបបថ្នាំទៀងទាត់ និងរបបថ្នាំបន្ថែមដែលគាត់អាចត្រូវការ) ការពិនិត្យតាមដានជាប្រចាំ និង និងការព្យាបាលតាមការចាំបាច់។

២. ការងារបន្តចាត់តាំងអ្នកមើលថែទាំ ដែលធ្លាប់មើលថែទាំ ខៀវ សំផន ក្នុងមន្ទីរ ឃុំឃាំងនៅ អ.វ.ត.ក ដើម្បីអាចឲ្យពួកគេអាចបន្តមើលថែទាំ ខៀវ សំផន នៅក្នុង ទីតាំងដែលគាត់នឹងបន្តឃុំក្នុងពន្ធនាគារខេត្តកណ្ដាល។

សូម ឯកឧត្តមប្រធាន លោក លោកស្រីចៅក្រម ទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១២ ខែមករា ឆ្នាំ ២០២៣ | ជា លាង<br>សហព្រះរាជអាជ្ញា | រាជធានីភ្នំពេញ | [signature] |
| | Fergal GAYNOR<br>**(បម្រុង)** | | [signature] |